**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០៦-សរណន**

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំខួបលើកទី៦០ "ទិវាកុមារអន្តរជាតិ ១ មិថុនា" និង ខួបលើកទី ៨ " ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា " ឆ្នាំ២០០៩

ក្នុងអំឡុងឆ្នាំ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី២ ពួកហ្វាសស៊ីសអ៊ីត្លែរបានបង្កវិនាសកម្មកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរាឌូប្រទេសបារាំង។ នៅខែមករាឆ្នាំ ១៩៤៩ អង្គប្រជុំមួយរបស់សហព័ន្ធនារីប្រជាធិបតេយ្យអន្តរជាតិបានអនុម័តយកថ្ងៃទី ១ មិថុនា ជារៀងរាល់ឆ្នាំសម្រាប់ទិវាកុមារអន្តរជាតិ ក្នុងគោលបំណងអោយមនុស្សជាតិចងចាំ និងរំងាប់អំពើហិង្សាដើម្បីថែរក្សាសន្តិភាពលើពិភពលោក។ ដោយឡែក ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ បានកើតមានចំពោះកុមារប្រមាណជាង ១០០ លាននាក់ អាយុពី ៥ ដល់ ១៧ឆ្នាំ។ ទម្រង់ទាំងនោះមាន ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ កុមារក្នុងជម្លោះប្រដាប់អាវុធ និងការប្រើប្រាស់កុមារក្នុងស្ថានភាពងាយរងគ្រោះ។ ដោយមូលហេតុនេះ ទើបអង្គការពលកម្មកុមារអន្តរជាតិសម្រេចយកថ្ងៃ១២ មិថុនា ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ។

សម័យប្រជុំពិសេសរបស់អង្គការសហប្រជាជាតិស្តីពីកុមារ នៅខែឧសភា ឆ្នាំ២០០២ បានចេញសេចក្តីប្រកាសរួមមួយឈ្មោះ " ពិភពលោកមួយសមស្របសម្រាប់កុមារ" ដែលបានកំណត់បញ្ហាអាទិភាពចំនួនបួនគឺ **មួយ** ការបង្កើនជីវភាពរស់នៅរបស់ស្ត្រី និងកុមារប្រកបដោយសុខភាពល្អ **ពីរ** ការបង្កើនគុណភាពអប់រំ **បី** ការប្រយុទ្ធប្រឆាំងមេរោគអេដស៍/ជំងឺអេដស៍ និង **បួន** កិច្ចការពារកុមាររួចផុតពីការរំលោភ ការកេងប្រវ័ញ្ច និងអំពើហិង្សា។ មហាសន្និបាតនៃអង្គការសហប្រជាជាតិលើកទី៦២ នៅខែធ្នូ ឆ្នាំ២០០៧ បានវាយតម្លៃលើកទឹកចិត្តដល់ប្រទេសទាំងឡាយដែលបានខិតខំអនុវត្តការងារទាំងនេះ ព្រមទាំងបានកំណត់ទិសដៅបន្ត។ ប៉ុន្តែនៅឆ្នាំ២០០៩នេះ នៅលើសាកលលោក នៅមានកុមារចំនួន ៧៥ លាននាក់នៅតែពុំទាន់បានចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សានៅឡើយ។ ការចុះឈ្មោះសរុបនៅ

ក៏រតថ្នាក់មធ្យមសិក្សាក្នុងប្រទេស កំពុងអភិវឌ្ឍន៍មាន ៦១% ជាកុមារា និង ៥៧% ជាកុមារី ហើយក្នុងប្រទេសអភិវឌ្ឍន៍តិចតួច តួលេខបានបង្ហាញថាមាន ៣២% ជាកុមារា និង ២៦% ជាកុមារី ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានជួបប្រទះ និងបានទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរបង្កឡើងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានធ្វើឱ្យប្រជាជន យុវជន កុមារ បាត់បង់សិទ្ធិជាមនុស្ស ត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ រស់នៅយ៉ាងសែនវេទនា រងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌អស់រាប់លាននាក់ ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេស សិទ្ធិរបស់កុមារនៅកម្ពុជាត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់ ដោយមានចែងច្បាស់ក្នុងរដ្ឋធម្មនុញ្ញ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ផ្តល់សច្ចាប័នលើពិធីសារពីរគឺ **: មួយ :** ការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ **ពីរ :** ការជួញដូរកុមារ ការធ្វើពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ នៅឆ្នាំ២០០២ ។ អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស នៅឆ្នាំ ២០០៧ ។ រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពី កម្ពុជាដើម្បីកុមារនៅឆ្នាំ ២០០៥ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជា ក៏បានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសវៀតណាម ប្រទេសថៃ និងកិច្ចព្រមព្រៀងបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ក្នុងការលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយជនរងគ្រោះ ។

រាជរដ្ឋាភិបាលបានបង្កើនសកម្មភាពនៃកិច្ចគាំទ្រ និងការពារដល់កុមារ ដើម្បីអនុវត្តឱ្យកាន់តែប្រសើរឡើងថែមទៀតនូវសិទ្ធិចម្បងទាំង ៤ របស់កុមារ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍន៍ និងសិទ្ធិក្នុងការចូលរួម និងដើម្បីលើកស្ទួយឧត្តមប្រយោជន៍របស់កុមារ ។ ទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ត្រូវបានចាត់តាំងឡើងជារៀងរាល់ឆ្នាំ ។ ស្ថានភាពមាតា ទារក ការអប់រំសិក្សា ការការពារកុមារប្រឆាំងនឹងអំពើរំលោភបំពានផ្សេងៗត្រូវបានយកចិត្តទុកដាក់ជំរុញឱ្យប្រសើរឡើងជាលំដាប់ ។ រាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យសង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀត ដែលធ្វើឱ្យសុខុមាលភាពប្រជាជន ពិសេសកុមារកាន់តែបានប្រសើរឡើង ។ ប៉ុន្តែទន្ទឹមនេះ កុមារកម្ពុជាក៏នៅប្រឈមនឹងបញ្ហាមួយចំនួនទៀត ដែលត្រូវរួមគ្នាខិតខំដោះស្រាយ ។ ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើងថែមទៀត រាជរដ្ឋាភិបាលណែនាំឱ្យរៀបចំទិវាកុមារអន្តរជាតិ ឆ្នាំ ២០០៩ នេះ ដូចតទៅ ÷

**១-អំពីប្រធានបទសំរាប់ទិវាកុមារអន្តរជាតិ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ឆ្នាំ ២០០៩ នេះគឺ :**

-ប្រធានបទនៃទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំនេះគឺ **"ផ្តល់ឱកាសឱ្យកុមារ ពិសេសកុមារីបានទទួលការអប់រំមូលដ្ឋាន ៩ឆ្នាំ"**

-ប្រធានបទនៃទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ឆ្នាំនេះគឺ **"ផ្តល់ឱកាសឱ្យកុមារីដើម្បីបញ្ចប់ពលកម្មកុមារ"**

២-ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ផ្សព្វផ្សាយជូនដល់សង្គមជាតិទាំងមូលឱ្យបានជ្រួតជ្រាបអំពីប្រវត្តិនៃទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ។

៣-គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទិញ ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកំសាន្តសប្បាយរបស់កុមារ នៅតាមគ្រឹះស្ថានសិក្សារដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល គ្រប់មណ្ឌលកុមារកំព្រា នៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានអធិកអធម ។

៤-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធត្រូវសហការរៀបចំមីទិញថ្នាក់ជាតិ និងមានកម្មវិធីកំសាន្តផ្សេងៗសម្រាប់កុមារនៅទីសាធារណៈ ឬរមណីដ្ឋានណាមួយសមស្របនៅរាជធានីភ្នំពេញ ឱ្យបានអធិកអធម ។

៥- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កលក្ខណៈផ្តល់ថវិកាសម្រាប់ការរៀបចំពិធីនេះឱ្យបានល្អ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី រាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តឱ្យបានប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ